**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មេត្តាជ្រាបថា **ពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប ៧ថ្ងៃ** ឧទ្ទិសកុសលជូនដល់ឧបាសក **ចាន់ ជី** ត្រូវជាឪពុកបង្កើតរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ដែលបានទទួលមរណភាពកាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ កន្លងទៅ នឹងប្រារព្ធធ្វើឡើងនៅថ្ងៃចន្ទ **១២កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ០៣:០០ នាទីរសៀល** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

កម្មវិធីបុណ្យនឹងប្រារព្ធនៅផ្ទះលេខ ២៥B ផ្លូវ៦៥៦ បុរីហាយធិច២ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

សេចក្តីដូចជម្រាបជូនខាងលើ សូមគោរព និងអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ ព្រមទាំងបងប្អូនញាតិមិត្តជិតឆ្ងាយទាំងអស់ចូលរួមក្នុង ពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប ៧ថ្ងៃ ដើម្បីចាប់មគ្គផលតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន៕

ថ្ងៃអាទិត្យ ១១កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងមុខងារសាធារណៈ *



# ពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប៧ ថ្ងៃ



ឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធ **ឧបាសក ចាន់ ជី**

## <u>អ្នកផ្តើមបុណ្យ</u>

- ឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងលោកជំទាវ ព្រមទាំងបុត្រធីតា និងចៅ
- លោកជំទាវវេជ្ជបណ្ឌិត **ព្រុំ ឆោម សាយឿន** ព្រមទាំងបុត្រ និងចៅ
- លោកស្រី **ខៀវ ចេតនា** ព្រមទាំងបុត្រ និងចៅ
- លោកស្រី **ចាន់ រដ្ឋា** និងលោក **សុខ សុវណ្ណា** ព្រមទាំងបុត្រ
- លោកស្រី **ចាន់ ពិរិន** និងលោក **ហេង ខុម**
- លោក **ចាន់ តារា** និងលោកស្រី **អ៊ិន សុខន** ព្រមទាំងបុត្រ
- លោក **ចាន់ វាសនា** និងលោកស្រី **សំ សុផល** ព្រមទាំងបុត្រ
- លោក **ចាន់ សុជាតិ** និងលោកស្រី **សុខ ម៉ាលី** ព្រមទាំងបុត្រ
- លោក **ចាន់ រតនា** និងលោកស្រី **ឡុង សុគន្ធា** ព្រមទាំងបុត្រ
- លោក **ចាន់ វិទ្យា** និងលោកស្រី **ហ៊ាង ណារី** ព្រមទាំងបុត្រ
- លោក **ចាន់ រស្មី** និងលោកស្រី **ទេព សាម៉ុឌី** ព្រមទាំងបុត្រ

## <u>សូមគោរពអញ្ជើញ</u>

ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងបងប្អូនញាតិមិត្តជិតឆ្ងាយទាំងអស់អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុង **ពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប ៧ ថ្ងៃ** ដើម្បីឧទ្ទិសកុសលជូនដល់ **ឧបាសក ចាន់ ជី** ត្រូវជាឪពុក ជីតា ជីតាទួត ដែលបានទទួលមរណភាពកាលពីថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ០៩:៤០នាទីយប់ ក្នុងជន្មាយុ ៩៦ ឆ្នាំ ដោយជរាពាធ។

## <u>កម្មវិធីបុណ្យ</u>

- **ថ្ងៃចន្ទ ១២កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ០៣:០០ នាទីរសៀល** ជួបជុំពុទ្ធបរិស័ទ និងបងប្អូនក្រុមគ្រួសារញាតិមិត្តជិតឆ្ងាយទាំងអស់ ដើម្បីប្រារព្ធបទនមស្សការ ព្រះរតនត្រ័យ សមាទានសីល រួចនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត និងសម្តែងធម៌ទេសនា។
- លុះព្រឹកឡើង **ថ្ងៃអង្គារ ១៣កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ០៩:០០ នាទីព្រឹក** និមន្តព្រះសង្ឃធ្វើពិធីរាប់បាត វេរភត្តាហារ និងប្រគេនទេយ្យវត្ថុដល់ព្រះសង្ឃជាកិច្ចបង្ហើយបុណ្យ។

ពិធីបុណ្យនេះប្រារព្ធនៅផ្ទះលេខ ២៥B ផ្លូវ៦៥៦ បុរីហាយធិច២ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា និងបងប្អូនញាតិមិត្តជិតឆ្ងាយទាំងអស់ អញ្ជើញចូលរួមក្នុងពិធីបុណ្យ ដើម្បីចាប់មគ្គផលតាមកំលាំងសទ្ធាជ្រះថ្លារៀងៗខ្លួនកុំបីអាក់ខានឡើយ។

ទំនាក់ទំនងម្ចាស់កម្មវិធីលេខៈ 012 811 977 / 012 320 409 / 016 811 977

សូមថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ
លោក លោកស្រី អ្នកនាង កញ្ញា ញាតិមិត្ត ដែលបានចូលរួមក្នុងពិធីបុណ្យរបស់យើងខ្ញុំ។